ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារដើម្បីសិក្សាការធ្វើវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារដើម្បីសិក្សាការធ្វើវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ ដែលមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១ រូប | អនុប្រធាន |
| ៣. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប | សមាជិក |
| ៤. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ០១ រូប | សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ០១រូប | សមាជិក |
| ៦. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប | សមាជិក |
| ៧. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ០១រូប | សមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់០១រូប | សមាជិក |
| ៩. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ០១រូប | សមាជិក |
| ១០. អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១. តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប | សមាជិក |

១២. ប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ សមាជិក
១៣. អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក
១៤. អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ សមាជិក
១៥. អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ ២.-**

ក្រុមការងារនេះ មានភារកិច្ចជាសេនាធិការផ្ទាជូនរាជរដ្ឋាភិបាល ក្នុងការសិក្សាស្រាវជ្រាវច្បាប់ស្តីពីសញ្ជាតិ ដើម្បីផ្តួចផ្តើមអំពីជម្រើសនានាក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ។

**ប្រការ ៣.-**

ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ក្រុមការងារនេះ មានសមត្ថកិច្ចដូចខាងក្រោម៖

- ប្រមែប្រមូលព័ត៌មានទាំងឡាយដែលបម្រើឲ្យការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ។
- អាចធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាស្ត្រាចារ្យ ជំនាញការតាមការចាំបាច់។
- អាចបង្កើតក្រុមលេខាធិការ ដើម្បីជួយការងាររបស់ខ្លួន តាមការចាំបាច់។
- ក្នុងការបំពេញការងាររបស់ខ្លួន ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងមហាផ្ទៃ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ដូចមានចែងនៅក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែ មាឃ ឆ្នាំ រកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ